# ព្រះសង្ឃនៅស្រុកសង្កែដាច់ចង្ហាន់នាំគ្នានិមន្តបិណ្ឌបាត្រស្រូវអង្ករនៅប៉ោយប៉ែត

ប៉ោយប៉ែត ៖ ព្រះសង្ឃនៅក្នុងស្រុកសង្កែខេត្តបាត់ដំបងបានបន្តមកបិណ្ឌបាត្រស្រូវអង្ករនៅឯក្រុងប៉ោយប៉ែតដោយសារតែទីអារាមនៅទីនោះរងនូវការខូចខាតទាំងស្រុងដោយសារទឹកជំនន់ក្នុងឆ្នាំ ២០១១កន្លងទៅ។ ព្រះសង្ឃដែលនៅទីនោះក៏បានដាច់ចង្ហាន់ស្ទើររាល់ថ្ងៃដែរ។

សូមបញ្ជាក់ផងដែរថា កាលពីព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០១២នេះ នៅតាមបណ្តោយផ្លូវជាតិលេខ លេខ៥ ពីប៉ោយប៉ែតមកខេត្តបន្ទាយមានជ័យ មានព្រះសង្ឃចំនួន៧អង្គ និងលោកយាយ លោកតាចំនួន៣នាក់ បានជិះគោយន្តតាមបណ្តោយផ្លូវជាតិលេខ៥ ក្នុងគោលបំណងនិមន្តបិណ្ឌបាត្រស្រូវ និង អង្ករ ដើម្បីយកទៅធ្វើចង្ហាន់សម្រាប់ពេលខាងមុខនេះ។

លោក អាចារ្យម្នាក់បានបញ្ជាក់ថា វត្តរបស់លោក ដែលកំពុងខ្វះខាតស្បៀងអាហារនេះ គឺមានឈ្មោះ វត្តតាប៉ុន ឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់ដំបង។ លោក អាចារ្យនេះបានបន្តទៀតថា វត្តរបស់លោក គឺជាវត្តបុរាណ ហើយឧត្យាហ៍រងគ្រោះដោយទឹកជំនន់រាល់ឆ្នាំ។ ដោយឡែកនៅក្នុងឆ្នាំ២០១១កន្លងទៅបានរងគ្រោះធ្ងន់ធ្ងរបំផុត។ នៅក្នុងវត្តមានព្រះសង្ឃចំនួន៣៨អង្គ យាយជីចំនួន៨នាក់។ ពេលនេះព្រះសង្ឃនិងលោកយាយ លោកតានាំគ្នានិមន្តតាមស្រុកភូមិឃុំឆ្ងាយៗអស់ទៅហើយ ដើម្បីរកស្រូវអង្ករសម្រាប់ទុកផ្គត់ផ្គង់នាពេលខាងមុខទៀត។ លោកយាយបានបន្តទៀតថា សម្រាប់ក្រុមរបស់លោក គឺមកដល់ក្រុងប៉ោយប៉ែត មានរយៈពេល៦ថ្ងៃហើយៗពលរដ្ឋនៅតាមភូមិបានប្រគេនស្រូវចំនួន៩ការ៉ុងស្មើនឹង៩០០គីឡូក្រាម៕

ពៅរី

ថ្ងៃពុធ ១១កើត ខែបុស្ស ឆ្នាំថោះត្រីស័ក ព.ស.២៥៥៥ ត្រូវនឹងថ្ងៃទី០៤ ខែមករា គ.ស.២០១២

ប្រភពព័ត៌មាន: សារព័ត៌មានកម្ពុជាថ្មី